# ធនាគារ ព្រីនស៍ ម.ក

## បញ្ញត្តិនិងលក្ខខណ្ឌសម្រាប់កម្មវិធីពិសេសលើកទឹកចិត្តចំពោះ រថយន្តអគ្គិសនីពីក្រុមហ៊ុន អាយខា (AIQAR) នៃការស្នើសុំឥណទានជាមួយធនាគារ ព្រីនស៍

តាមរយៈការស្នើសុំឥណទានរថយន្តអគ្គិសនីពីក្រុមហ៊ុន អាយខា (AIQAR) នៅអំឡុងរយៈពេលកម្មវិធីលើកទឹកចិត្តនេះ អតិថិជនយល់ព្រមអនុវត្តតាមបញ្ញត្តិ និងលក្ខខណ្ឌដូចខាងក្រោម ("**កម្មវិធីលើកទឹកចិត្ត**") ព្រមទាំងគោលនយោបាយឥណទាន និងគោលនយោបាយ និងនីតិវិធីដែលពាក់ព័ន្ធរបស់ធនាគារ ព្រីនស៍ ម.ក ("**ធនាគារ ព្រីនស៍**")៖

១. រាល់អតិថិជន អាចដាក់ពាក្យសុំ ឥណទានរថយន្តអគ្គិសនីម៉ូដែលថ្មី ពីក្រុមហ៊ុន អាយខា (AIQAR) តែប៉ុណ្ណោះ ("**អតិថិជន**")។

២. ក្នុងករណីពាក្យស្នើសុំឥណទានរថយន្តអគ្គិសនីម៉ូដែលថ្មីរបស់អតិថិជន ត្រូវបានដាក់ក្នុងអំឡុងរយៈពេលកម្មវិធីលើកទឹកចិត្តនេះ ត្រូវបានអនុម័តយល់ព្រមដោយធនាគារ ព្រីនស៍ ទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន អតិថិជនអាចទទួលបានការផ្តល់ជូននូវអត្ថប្រយោជន៍ស្របតាមបញ្ញត្តិ និងលក្ខខណ្ឌខាងក្រោម៖

| ការផ្តល់ជូន | លក្ខខណ្ឌ | រយៈពេលនៃកម្មវិធីលើកទឹកចិត្ត (ថ្ងៃដាក់ស្នើសុំ) |
|---|---|---|
| **កម្មវិធីពិសេស ចំពោះ រថយន្តអគ្គិសនីពីក្រុមហ៊ុន អាយខា (AIQAR)** | | |
| **<u>កម្មវិធីពិសេស ៥&៥៖</u>**<br><br>✓ អត្រាការប្រាក់៖ **៥% ក្នុងមួយឆ្នាំ**<br>✓ រយៈពេលរំលស់៖ បានរហូតដល់ **៥ ឆ្នាំ**<br>✓ ទំហំឥណទានផ្តល់ជូន៖ បានរហូតដល់ ៨០% **នៃតំលៃរថយន្ត**<br>✓ រយៈពេលហាមឃាត់៖ **លើកលែង សំរាប់ការរំលស់ដើមខ្លះ ឬបង់ផ្តាច់មុនកំណត់**<br><br>**<u>កម្មវិធីពិសេស ៧&៧៖</u>**<br><br>✓ អត្រាការប្រាក់៖ **៧% ក្នុងមួយឆ្នាំ**<br>✓ រយៈពេលរំលស់៖ បានរហូតដល់ ៧ **ឆ្នាំ**<br>✓ ទំហំឥណទានផ្តល់ជូន៖ បានរហូតដល់ **៨៥% នៃតំលៃរថយន្ត**<br>✓ រយៈពេលហាមឃាត់៖ **៣% សំរាប់ការរំលស់ដើមខ្លះ ឬបង់ផ្តាច់មុនកំណត់** | - សំរាប់អតិថិជនមានបំណងទិញរថយន្តអគ្គិសនីម៉ូដែលថ្មី ម៉ាក អាយខា<br>- ទំហំឥណទានផ្តល់ជូន៖ អតិបរមា ៦០.០០០ដុល្លារ<br>- ទ្រព្យធានា៖ ប័ណ្ណសម្គាល់ម្ចាស់រថយន្ត ដែលបានទិញចុះបញ្ជីក្រោមឈ្មោះអតិថិជន<br>- របៀបសង៖ បង់ថេររៀងរាល់ខែ<br>- កំរៃអនុម័តឥណទាន៖ ១%<br>- សេវាផ្សេងៗ៖ យកតាមជាក់ស្តែងពីអតិថិជន<br>- ប្រភពចំណូលពី៖ ប្រាក់បៀវត្សរ៍ អាជីវកម្ម និង ការជួលផ្សេងៗ (យោងតាមគោលការណ៍ឥណទាន)<br>- របាយការណ៍នៃចំណូល៖ រហូតដល់ ៣ខែចុងក្រោយ<br>- បញ្ញត្តិ និងលក្ខខណ្ឌនៃសំណុំឯកសារ ឥណទាននៃធនាគារ ព្រីនស៍ ត្រូវអនុវត្ត | មានប្រសិទ្ធិភាពចាប់ពី៖ ថ្ងៃទី ១៥ ឧសភា ២០២៤ រហូតដល់ មានការជូនដំណឹងសារថ្មី |

៣. **ការរក្សាសិទ្ធិ ការរួចផុត និងការកម្រិតនៃការទទួលខុសត្រូវ**

ក. អតិថិជន យល់ព្រមថា ធនាគារ ព្រីនស៍ រួមបញ្ចូលទាំង ម្ចាស់ភាគហ៊ុន អភិបាល ឬបុគ្គលិករបស់ ធនាគារ ព្រីនស៍ មិនត្រូវទទួលខុសត្រូវលើ រាល់ការខូចខាតណាមួយ ទោះដោយផ្ទាល់ ឬដោយប្រយោល ជាពិសេស ឬដោយចៃដន្យ ដែលកើតឡើងទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះឡើយ។

ខ. អតិថិជន យល់ព្រមដោយមិនដកវិញថា អតិថិជនយល់ព្រមសងសំណង និងធានាថា ធនាគារ ព្រីនស៍ នឹងទទួលបានសំណងគ្រប់ពេលណាមួយ លើរាល់ការបាត់បង់ ការខូចខាត កម្រៃសេវា កម្រៃសេវាផ្លូវច្បាប់ និងការចំណាយផ្សេងៗ និងរាល់វិបាកដែលកើតឡើងលើ ធនាគារ ព្រីនស៍ ឬបានទទួលរងដោយ ធនាគារ ព្រីនស៍ ចំពោះការទាមទារ ឬបណ្តឹងណាមួយដែលធ្វើឡើងដោយ អតិថិជន ឬភាគីទីបី ដែលកើតឡើង ឬទាក់ទងនឹងបញ្ញត្តិដែលមានចែងក្នុងបញ្ញត្តិនិងលក្ខខណ្ឌនេះ។

៤. ក្នុងករណីមានការឆបោក ឬក្លែងបន្លំដែលប្រព្រឹត្តដោយ ឬមានពាក់ព័ន្ធនឹងអតិថិជនទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ អតិថិជនរូបនោះនឹងបាត់បង់សិទ្ធិចូលរួមកម្មវិធីលើកទឹកចិត្តនេះ ដោយរួមទាំងអត្ថប្រយោជន៍ផ្សេងៗដែលខ្លួនទទួលបាន។ អតិថិជន ត្រូវប្រគល់ជូន ធនាគារ ព្រីនស៍ វិញ នូវរាល់អត្ថប្រយោជន៍ដែលខ្លួនបានទទួលពី ធនាគារ ព្រីនស៍ តាមរយៈកម្មវិធីលើកទឹកចិត្តនេះ (ប្រសិនបើមាន) និងត្រូវសងសំណងការខូចខាតផ្សេងៗទៅតាមបញ្ញត្តិច្បាប់ជាធរមាន។

៥. ធនាគារ ព្រីនស៍ រក្សាសិទ្ធិគ្រប់យ៉ាង ក្នុងការធ្វើវិសោធនកម្មលើបញ្ញត្តិនិងលក្ខខណ្ឌនេះ ពន្យាពេល បន្ថែមរយៈពេល ឬលុបចោលកម្មវិធីលើកចិត្តនេះ និង/ឬអត្ថប្រយោជន៍ដែលផ្តល់ជូន នៅពេលណាមួយក្នុងរយៈពេលនៃកម្មវិធីលើកទឹកចិត្ត ដោយមិនមានការទទួលខុសត្រូវ តាមរយៈការជូនដំណឹងពីការផ្លាស់ប្តូរ នៅលើគេហទំព័រផ្លូវការ ឬតាមមធ្យោបាយទំនាក់ទំនងដែលមានផ្សេងទៀតរបស់ ធនាគារ ព្រីនស៍។

៦. បញ្ញត្តិនិងលក្ខខណ្ឌនេះ ត្រូវបានគ្រប់គ្រងដោយច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ រាល់វិវាទដែលកើតឡើង ឬទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ នឹងត្រូវបានដោះស្រាយ ដោយអនុលោមតាម គោលនយោបាយដោះស្រាយបណ្តឹងអតិថិជនរបស់ ធនាគារ ព្រីនស៍ និងតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។